**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

លេខៈ ១២ [illegible]

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០១០

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ**

**សូមគោរពជូន**

**ឯកឧត្តម លោកជំទាវ**

**ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** ករណីការផ្អាកដំណើរការសាលចតុម្មុខ រយៈពេល៤០ ថ្ងៃ ដើម្បីរៀបចំបណ្តាញភ្លើង និងជួសជុលម៉ាស៊ីនត្រជាក់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ** គ្រប់ក្រសួងស្ថាប័នទាំងអស់មេត្តាជ្រាបថាៈ ដើម្បីរៀបចំបណ្តាញភ្លើង និងជួសជុលម៉ាស៊ីត្រជាក់នៅសាលចតុម្មុខ ដែលបច្ចុប្បន្នមានភាពរអាក់រអួលឱ្យដំណើរការជាប្រក្រតីឡើងវិញនោះ ក្រសួងវប្បធមិ និងវិចិត្រសិល្បៈសូមផ្អាកការប្រើប្រាស់សាលចតុម្មុខ រយៈពេល៤០ ថ្ងៃ គឺចាប់ពីថ្ងៃទី២០ ខែឧសភា រហូតដល់ថ្ងៃទី៣១ ខែមិថុនា ឆ្នាំ២០១០។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ ខ្ញុំសូម **ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ** គ្រប់ក្រសួងស្ថាប័នទាំងអស់មេត្តាជ្រាបតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ** គ្រប់ក្រសួងស្ថាប័នទាំងអស់មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**<u>ចម្លងជូនៈ</u>**

- ខុទ្ទកាល័យ **សម្តេច** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាតិ
- អគ្គលេខាធិការដ្ឋានរដ្ឋសភាជាតិ
- ខុទ្ទកាល័យ លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ

"<u>ដើម្បីជូនជ្រាប</u>"។

- ឯកសារ

Kh 009 In.06-2010

# ព្រះរាជាណាចក្រកម្ពុជា

ROYAUME DU CAMBODGE

ព្រះបរមរាជវាំង

លេខ : ៧៤៤/រវ.សជណ
/១០

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០

**សម្តេចចៅហ្វាវាំង ធរសៀងជ័យ អធិបតីស្រីវង្ការ**
**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**
សូមជំរាបជូន
**ឯកឧត្តម ថាច់ សេដ្ឋា**
**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**កម្មវត្ថុ** : អំពីសំណើសូមព្រះបរមរាជានុញ្ញាត យាងព្រះរាជតំណាងជាព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបុណ្យរាប់បាត្រព្រះសង្ឃ ១៩៨៩អង្គ នៅសួនច្បារមុខវត្តបទុមវតី ។

**យោង** :- ព្រះរាជតម្រិះដ៏ខ្ពង់ខ្ពស់របស់ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ។
- លិខិតលេខ ០៧/១០ ស.ខ.ក.ក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ របស់សហគមន៍ខ្មែរកម្ពុជាក្រោម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយស សូមជំរាបជូនឯកឧត្តម ជ្រាបថា **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គសព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទាន **សម្តេច ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស** ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់ ក្នុងពិធីបុណ្យរាប់បាត្រព្រះសង្ឃ ១៩៨៩ អង្គ ដែលរៀបចំឡើងដោយសហគមន៍ខ្មែរកម្ពុជាក្រោម នៅព្រឹកថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០១០ នៅសួនច្បារមុខវត្តបទុមវតី ។

អាស្រ័យដូចបានជំរាបជូនខាងលើនេះ សូមឯកឧត្តម មេត្តាជ្រាប តាមការគួរ ។

សូម ឯកឧត្តម មេត្តាទទួលនូវការរាប់អានដ៏ស្មោះ អំពីខ្ញុំ ។

**ត. ប. សម្តេចចៅហ្វាវាំង ធរសៀងជ័យ អធិបតីស្រីវង្ការ**
**ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង**
**រដ្ឋលេខាធិការក្រសួងព្រះបរមរាជវាំង**

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះបរមរាជវាំង

**ឈា ឆាន**

**ចម្លងជូន**
- គ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងព្រះបរមរាជវាំង "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# សហគមន៍ខ្មែរកម្ពុជាក្រោម
**KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**

**លេខ ១១/១០ ស.ខ.ក.ក.**

## គោរពជូន
## ឯកឧត្តមអភិបាលរាជធានីភ្នំពេញ

*កម្មវត្ថុ:* ស្នើសុំ ពហុកីឡាដ្ឋានជាតិ អូឡាំពិច ធ្វើបុណ្យរាប់បាត្រព្រះសង្ឃ១៩៤៩អង្គ

*យោង:* លិខិតលេខ២៨៥ ឆត.អធិ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ របស់សាលារាជធានីភ្នំពេញ

: លិខិតជូនដំណឹងលេខ១៥ ស.ជ.ណ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមអភិបាលរាជធានីភ្នំពេញមេត្តាជ្រាបថាកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០ សហគមន៍ខ្មែរកម្ពុជាក្រោម បានធ្វើលិខិតជាផ្លូវការមួយច្បាប់ ស្នើសុំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាលសន្និសីទចតុមុខ តាមការណែនាំរបស់សាលារាជធានីភ្នំពេញ ប៉ុន្តែក្រសួងបានផ្ញើលិខិតជូនដំណឹងមួយច្បាប់មកវិញថា កំពុងជាប់ជួសជុល។ ដូច្នេះ សហគមន៍ខ្មែរកម្ពុជាក្រោមមកដល់ពេលនេះ ពុំទាន់មានទីកន្លែងសមរម្យណាមួយសំរាប់ប្រារព្ធពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ នៅថ្ងៃទី០៤ ខែ មិថុនា ឆ្នាំ២០១០ ខាងមុខនេះនៅឡើយទេ។

អាស្រ័យហេតុនេះ សហគមន៍ខ្មែរកម្ពុជាក្រោម សូមអនុញ្ញាតស្នើសុំឯកឧត្តមសាជាថ្មីម្តងទៀត នៅពហុកីឡាដ្ឋានជាតិអូឡាំពិច ឬកន្លែងផ្សេងណាមួយទៀត ដែលឯកឧត្តមយល់ឃើញថាអាចប្រារព្ធពិធីបុណ្យរាប់បាត្រនេះបាន ដើម្បីយើងខ្ញុំ បានរៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន១៩៤៩អង្គ ដូចរៀងរាល់ឆ្នាំ។

សហគមន៍ខ្មែរកម្ពុជាក្រោម មានសេចក្តីសង្ឃឹមយ៉ាងមុតមាំថា ឯកឧត្តមអភិបាលរាជធានីភ្នំពេញពិតជាមានការយោគយល់ និងអាណិតអាសូរដល់សហគមន៍ខ្មែរកម្ពុជាក្រោម ដោយផ្តល់ទីកន្លែង ពហុកីឡាដ្ឋានជាតិអូឡាំពិច ឬទីកន្លែងសមរម្យណាមួយផ្សេងទៀត ដល់សហគមន៍ខ្មែរកម្ពុជាក្រោម ដើម្បីប្រារព្ធពិធីបុណ្យដូចបានជំរាបជូនខាងលើ និងផ្តល់នូវកិច្ចការពារសន្តិសុខដល់ពិធីបុណ្យជាក់ជាមិនខាន។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១០

នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម

THE KHMER KAMPUCHEA KROM COMMUNITY

ថាច់ សេដ្ឋា

ក្រុមប្រឹក្សារាជធានីភ្នំពេញ

អតីតសមាជិកព្រឹទ្ធសភា

ទីស្នាក់ការបណ្ដោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៩៣៣ ០០៣
E-mail: senthach2000@yahoo.com; Website: http//khmerkromngo.org